# សន្និសីទលើកទី២ស្តីពីកសិកម្មនៅអាស៊ីរបស់ ECHO
## ខេត្តឈៀងម៉ៃ ប្រទេសថៃ
## ថ្ងៃទី២១-២៥ ខែកញ្ញា ឆ្នាំ២០០៩

យើងកំពុងតែមមាញឹកធ្វើការរៀបចំសន្និសិទស្តីពីកសិកម្មនៅអាស៊ីរបស់ ECHO ។ មានបញ្ជីឈ្មោះរបស់វាគ្មិនដែលត្រូវបង្ហាញអំពីប្រធានបទដែលគួរឲ្យចាប់អារម្មណ៍ដូចជា:

- ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស)
- ផ្ទះធ្វើអំពីដី
- ថាមពល ដែលយកមកប្រើជំនួសឲ្យប្រេងឥន្ធនៈ ឬមិនប៉ះពាល់ដល់បរិស្ថាន សំរាប់សហគមន៍ដាច់ស្រយាល
- ការធ្វើទឹកស្អាត។

បន្ថែមពីលើនេះ មានបណ្តាញរបស់ ECHO ជាច្រើនដែលបានស្នើសុំឲ្យមានការរៀបចំសិក្ខាសាលាដែលទាក់ទងទៅនឹងជំពីសផ្សេងៗគ្នានៃការអភិវឌ្ឍន៍ និងសកម្មភាពកាត់បន្ថយភាពអត់ឃ្លាន។

កន្លែងមានកំណត់ចុះឈ្មោះឥឡូវសំរាប់សន្និសិទគួរឲ្យភ្ញាក់ផ្អើលនេះ! តាមការទាក់ទងនៅខាងក្រោម "ការទាក់ទងយ៉ាងឆាប់រហ័ស" "Quick Links" (នៅលើខាងស្តាំ) សំរាប់ព័ត៌មានផ្សេងទៀត, បញ្ជីឈ្មោះ និងការចំណាយ។

ជួបគ្នាក្នុងខែកញ្ញា!

**ECHO (Educational Concerns for Hunger Organization)**

# មកដល់អាស៊ីអាគ្នេយ៍

រៀបរាងដោយ **Stan Doerr** ប្រធាននិងជានាយកចាត់ការទូរទៅ ECHO អន្តរជាតិ



នេះគឺជាកិត្តិយសរបស់ខ្ញុំដើម្បីណែនាំឲ្យអ្នកស្គាល់ការចេញផ្សាយ ជាលើកដំបូងស្តីពី **ECHO** អាស៊ី **(EAN)** ។ **ECHO** បានកំពុងផ្តល់នូវការគាំទ្របច្ចេកទេសកសិកម្ម តំបន់ត្រូពិចដ៏ត្រឹមត្រូវ និងមានសុពលភាពអស់រយះពេលជាង ២៨ឆ្នាំមកហើយ។ បច្ចុប្បន្ននេះពួកយើងកំពុងតែ ធ្វើការជាមួយអង្គការជាង ៣០០០ ក្នុង ១៨០ប្រទេស។ នៅពេលថ្មីៗនេះដែរយើងបានយល់ច្បាស់ពីភាពចាំបាច់ដើម្បីធ្វើសកម្មភាព និងគិតគូរទៅដល់អនាគតឲ្យបានច្រើន ក្នុងគោលបំណងបញ្ជាក់ឲ្យ ដឹងច្បាស់ថាធនធានរបស់ **ECHO** គឺមានភាពងាយស្រួលដែលអាចធ្វើការជាមួយប្រជាជនក្រីក្រ នៅជុំវិញពិភពលោក។ យើងក៏ដឹងហើយថា មានរឿងជោគជ័យ ដែលមិនគួរឲ្យជឿមួយចំនួន ថាតើការរស់នៅរបស់ប្រជាជន មានភាពប្រសើរឡើងតាមវិធីបែបណា ដោយគ្រាន់តែផ្អែកលើ ការងារដែលត្រូវបានគេធ្វើនៅជុំវិញពិភពលោក ទៅលើកសិកម្មតំបន់ត្រូពិចនោះ។ ប្រសិនបើយើងអាចស្វែងរកបាននូវភាពជោគជ័យទាំងនោះមែន បន្ទាប់មកយើងក៏អាចចែករំលែក ទៅកន្លែងផ្សេងៗទៀត ដែលមិនទាន់បានអនុវត្តនី ដូច្នេះការរស់នៅមួយភាគធំរបស់ប្រជាជននឹងបានប្រសើរឡើង។

ដើម្បីបំពេញគោលដៅនេះហើយ និងមានការប្រាកដថា អ្នកអាចយកមកប្រើប្រាស់បានយ៉ាងងាយស្រួលនូវធនធានរបស់ **ECHO** តាមរយៈភាសាដែលទាក់ទងមួយចំនួននោះ។ **ECHO** បានបើកការិយាល័យថ្នាក់តំបន់មួយឡើងក្នុងខេត្តឈៀងម៉ៃ ប្រទេសថៃ ដើម្បីបំពេញសេចក្តីត្រូវការនៅអាស៊ីអាគ្នេយ៏ក្នុងតំបន់ខ្លះនៃកសិកម្មតំបន់ត្រូពិច និងបច្ចេកវិជ្ជាសមរម្យមួយចំនួនទៀត។

ការិយាល័យតំបន់នេះនឹងផ្តល់នូវសេវាកម្មទាំងអស់របស់ **ECHO** រួមមានឱកាសទទួលបានការហ្វឹកហ្វឺនជាច្រើនការបង្កើនសមត្ថភាព និងភាពអង់អាច នៃក្រុមការងារអភិវឌ្ឍន៍សហគមន៍អន្តរជាតិ ដោយបង្កើតជាបណ្តាញដើម្បីបង្កើននូវជំនាញ និងចំណេះដឹង ឲ្យពួកគេបានផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកតាមរយៈការប្រជុំនិងការគាំទ្រផ្នែកបច្ចេកទេសមានដូចជាគ្រាប់ពូជនៃដើមឈើហូបផ្លែ, បន្លែ, និងប្រភេទនៃការដាំដើមឈើ និងដាំដំណាំកសិកម្មលើប្រភេទដីដូចគ្នានៃតំបន់ត្រូពិចដ៏មានតំលៃ។

នៅពេលការយល់ដឹងជ្រួតជ្រាបមានការកើនឡើង ច្បាប់ចេញផ្សាយ **EAN** បន្ថែម **EDN** និងត្រូវផ្តល់ឲ្យអ្នកជាមួយជំរើសផ្នែកកសិកម្ម មានសំរាយយ៉ាងក្បោះក្បាយ ដែលអ្នកអាចយកទៅអនុវត្តន៍ដើម្បីជួយបង្កើនគុណភាពជីវិត ក្នុងសហគមន៍របស់អ្នក។ ហើយយើងនឹងធ្វើការបកប្រែជាច្រើនភាសានៅលើឯកសារទាំងនោះ។

ប្រសិន **EAN** នេះជួយអ្នកពិតប្រាកដមែន សូមចែករំលែកពិសោធន៍នេះជាមួយមិត្តរបស់អ្នក ហើយឲ្យពួកគេទាក់ទង មកការិយាល័យនៅអាស៊ីតាម E-mail: echoasia@echonet.org ដើម្បីឲ្យប្រាកដថា ពួកគេទទួលបាននូវច្បាប់ចម្លងជារបស់ពួកគេហើយ។ បើសិនអ្នកមានសំនួរ ឬយោបល់សូមទាក់ទង មកនាយកតំបន់ទទួលបន្ទុក **ECHO** តំបន់អាស៊ី តាម Email: rburnette@echonet.org និង echoasia@echonet.org ។

ព្រះជាម្ចាស់ប្រសិទ្ធិពរឲ្យអ្នកក្នុងការងាររបស់អ្នក។ សេចក្តីប្រាថ្នារបស់ពួកយើង គឺត្រូវការជួយអ្នកឲ្យធ្វើនូវការងាររបស់អ្នកបានល្អដោយផ្តល់ឲ្យអ្នកនូវធនធានកសិកម្មដែលអ្នកត្រូវការចាំបាច់។

# ដំណាំផ្ទីគ្រាប់ (Amaranth) មានសក្តានុពលសំរាប់ការដាំដុះនៅតំបន់ខ្ពង់រាបនៃភូមិភាគអាស៊ីអាគ្នេយ៍ផ្អែកលើបទពិសោធន៍ទទួលបាននៅអាហ្វ្រិកភាគខាងកើត

## សក្តានុពលនៃដំណាំផ្ទីគ្រាប់សំរាប់តំបន់ខ្ពង់រាបនៃភូមិភាគអាស៊ីអាគ្នេយ៍



តាមបទពិសោធន៍របស់ CRWRC និងដៃគូសហការនៃអង្គការ នៅអាហ្វ្រិក ភាគខាងកើត បានបង្ហាញពីដំណាំផ្ទីគ្រាប់ ដែលមានសក្តានុពលយ៉ាងល្អប្រសើរ នៅតំបន់ខ្ពង់រាប នៃភូមិភាគអាស៊ីអាគ្នេយ៍។ ដំណាំផ្ទីគ្រាប់ សំបូរទៅដោយប្រូតេអ៊ីនច្រើននិងសារធាតុចិញ្ចឹមសំរាប់ទ្រទ្រង់រាងកាយមនុស្ស។ ក្នុងតំបន់ខ្លះនៅអាស៊ីអាគ្នេយ៍ ដែលបង្កបង្កើនផលស្រូវ ដាំស្រូវចំការ ការផ្គត់ផ្គង់ស្រូវមិនគ្រប់គ្រាន់សំរាប់ទទួលទាន (ឧ. ក្នុងចំណោមកូនក្មេងនៅភាគខាងជើងប្រទេសឡាវ ៥០% មានការលូតលាស់មិនសូវល្អ) ។ ប្រសិនមានដំណាំផ្ទីគ្រាប់ សំរាប់បរិភោគបន្ថែមតិចតួចរាល់ថ្ងៃនោះ វានឹងជួយទ្រទ្រង់រាងកាយបានច្រើន។ ជាឧទាហរណ៍ក្នុងការសិក្សាមួយនៅប្រទេសម៉ិកស៊ិក្ វ បានរកឃើញថា យ៉ាងតិច ២០ក្រាមនៃម្សៅផ្ទីផ្តល់ឲ្យក្មេងម្នាក់ ក្នុងមួយថ្ងៃ (ប្រមាណជា ២.៥ ស្លាបព្រាបាយ) បានផ្តល់ប្រយោជន៍ដ៏សំខាន់ដល់ការលូតលាស់របស់ក្មេង។ ជាការពិតដែលថាផ្ទីគ្រាប់គឺជាដំណាំ ដែលធន់នឹងភាពរាំងស្ងួតកំរិតខ្ពស់បានសេចក្តីថា វាមានសក្តានុពលជាប្រភេទដំណា ដែលដុះលើដីទំនេរ ដែលមិនអាចមានដំណាំអ្វីផ្សេងទៀតអាចដុះលូតលាស់បាន ឬជាដំណាំបន្ទិលដែលត្រូវបានគេដាំនៅចុងរដូវភ្លៀង។ នៅអាស៊ីអាគ្នេយ៍ ទោះជាកសិករយកមកដាំបានទទួលជោគជ័យសំរាប់ការបរិភោគ ក្នុងគ្រួសារក៏ដោយ វាទាមទារនូវការបណ្តុះបណ្តាលពីវិធីសាស្ត្រនៃការដាំដុះនិងការគាំទ្រពីបុរសនិងស្ត្រីក្នុងគ្រួសារកសិករដែរ។ ដំណាំនេះត្រូវការពន្លឺថ្ងៃប្រែប្រួលតាមវគ្គលូតលាស់ (ឧ. ពេលផលាចេញផ្កាត្រូវការពន្លឺថ្ងៃខ្លី)។ កសិករ

បានយល់ដឹង និងចេះពីរបៀបចំអិនស្លឹកប៉ុន្តែខ្វះខាតនូវចំណេះដឹងពីវិធីចំអិនគ្រាប់។ ម៉្យាងទៀត ផ្ទីគ្រាប់នេះមានផលប្រយោជន៍សំខាន់គឺវាមានរស់ជាតិធម្មតាគ្រាប់តូច ហើយអាចលាយបញ្ចូល ជាមួយគ្រាប់ធញ្ញជាតិដទៃទៀតបានល្អ ជាពិសេសលាយជាមួយគ្រាប់អង្ករ។ ដូចគ្នាដែរ ស្លឹកក៏អាចបរិភោគបានដែរ ពីព្រោះស្លឹកវាអាចធ្វើជាបន្លែ ដែលជាការពេញនិយម ក្នុងការយកទៅបរិភោគ។ ទោះបីស្លឹករបស់វាមានសារធាតុចិញ្ចឹម អាចជួយទ្រទ្រង់រាងកាយបានល្អ ក៏នៅចាញ់គ្រាប់របស់វាដែរ។ គ្រាប់ផ្ទីនេះសំបូរទៅដោយសារធាតុចិញ្ចឹមដូចជា វីតាមីន, កាល់ស្យូម, ខ្លាញ់ និងប្រូតេអ៊ីន កំរិតខ្ពស់ (ប្រហែល ១២~១៦% នៃប្រូតេអ៊ីនសរុប) ជាពិសេសក្នុងគ្រាប់ផ្ទីនេះមានសារធាតុចិញ្ចឹមដ៏សំខាន់ឡេស៊ីន (Lysine) សំបូរជាងក្នុងគ្រាប់ធញ្ញជាតិផ្សេងទៀត ដែលធាតុចិញ្ចឹមទាំងនេះផ្តល់ការទ្រទ្រង់ ចំពោះរាងកាយមនុស្ស ប្រសិនយើងបរិភោគលាយ១ភាគ នៃគ្រាប់ផ្ទីជាមួយ ៣ទៅ ៥ភាគនៃ គ្រាប់ធញ្ញជាតិដទៃទៀតដែលជាអាហារសំខាន់ដូចជា អង្ករ ឬពោតនោះ។ គ្រួសារកសិករភាគច្រើនបំផុត នៅអាហ្វ្រិកភាគខាងកើត គ្រាន់តែកិនគ្រាប់ផ្ទី ជាម្សៅក្រោយមកយក វាច្របល់ជាមួយម្សៅពោត ដោយប្រើវិធីលាយតាមបរិមាណដូចខាងលើ។

(លោក Ray Heinecke ជាអ្នកវិទ្យាសាស្ត្រខាងផ្នែកចំណីអាហារដែលបានចូលនិវត្តន៍ ហើយជាអ្នកដែលបានសិក្សាពីគ្រាប់ធញ្ញជាតិផ្ទីនេះបានពន្យល់ថា គ្រាប់ផ្ទីនេះត្រូវបានគេចូលចិត្តយកទៅលីង ហើយយកទៅលាយជាមួយគ្រាប់ធញ្ញជាតិ ដែលមានសារធាតុទ្រទ្រង់រាងកាយទាប (អង្ករ ឬពោត)។ ការលីងគ្រាប់នេះ ធ្វើឲ្យអាហារមានភាពខាប់អន្ទិល ដោយសារតែជាតិកាបូនហាយដ្រេត ទាំងអស់ត្រូវបានរលាយចូលគ្នា។ បើសិនចង់ធ្វើឲ្យអាហារនេះខាប់អន្ទិលសព្វ ដោយមិនចាំបាច់លីង គ្រាប់ផ្ទីនោះត្រូវចំណាយពេលវេលា ចំអិនយូរជាងធម្មតា ពីព្រោះគ្រាប់វាណែន ហើយតូច ហើយធ្វើឲ្យជាតិកាបូនហាយដ្រេតរលាយតិចតួច។ ប្រសិនបើការលីងគ្រាប់ផ្ទីនោះគឺមិនអាចទៅរួចទេការប្រើគ្រាប់ធម្មតា គឺស្មើរតែល្អដូចគ្នា។ ក្នុងករណីខ្លះការកិនក៏អាចបាត់បង់ចំណែកតូចៗនៃម្សៅនេះដែរ។ ដូច្នេះប្រសិនជា យើងមិនបានលីងឬកិនទេការចំអិនចាប់ពី ៣០នាទី ឬយូរជាងនេះក៏អាចធ្វើឲ្យខាប់បានដែរ។

ស្លឹកអាចត្រូវបានគេរៀបចំ សំរាប់ចំអិនទៅតាមទំលាប់ ក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយវិធីល្អបំផុតគួរតែដាំវាសំរាប់យកស្លឹកផ្សេង និងយកគ្រាប់ផ្សេងធ្វើដូចនេះយើងអាចចំណេញ

ដោយមិនមានការបាត់បង់ស្លឹក។ នៅអាស៊ីអាគ្នេយ៍ ពេលវេលានៃកាដាំដុះសំរាប់គ្រាប់ផ្ទីត្រូវអនុវត្តន៏ទៅតាមកត្តាមួយចំនួនដូចជា:

- ប្រភេទពូជផ្ទីគ្រាប់ពេលចេញផ្កានិងចេញគ្រាប់ត្រូវឲ្យចំពេលពន្លឺថ្ងៃខ្លី គឺឲ្យមុន ថ្ងៃទី២១ ខែធ្នូ ក្នុងតំបន់ភាគខាងជើងអេក្វាទ័រ ហើយបូករួមទាំងតំបន់អាស៊ីអាគ្នេយ៍ស្ទើរតែទាំងអស់ផង។ ការដាំដុះប្រភេទរុក្ខជាតិទាំងនេះ ប្រើពេល ៧៥ថ្ងៃទើបអាចប្រមូតកាត់បាន។
- រុក្ខជាតិផ្ទីគ្រាប់ដុះពន្លកល្អបំផុតលើដីដែលមានសីតុណ្ហភាពក្តៅល្មម (តំរូវការសីតុណ្ហភាពល្មមនៅពេលយប់) ហើយលូតលាស់ល្អបំផុតនៅតំបន់ ដែលមានខ្យល់ស្ងួតជាមួយនិងសំណើម ដីគ្រាប់គ្រាន់។
- កាលណា ឬសកែវដុះមក (បន្ទាប់ពីដាំ៣សប្តាហ៍) ដំណាំគឺអាចធន់នឹងភាពរាំងស្ងួតខ្លាំង
- ភ្លៀងមូសសុងនៅអាស៊ីអាគ្នេយ៍ (ឧ. អឌ្ឍគោលខាងជើង) ថយចុះក្នុងខែវិច្ឆិកា និងធ្នូ ហើយជាទូទៅបញ្ចប់វិញមិនហួសខែមករាជាមួយសីតុណ្ហភាពពេលយប់ និងថ្ងៃក៏ត្រជាក់ដែរ។

## ការណែនាំចំពោះពេលវេលាដាំដុះ



គោលបំណងសំខាន់ ដើម្បីដាំដំណាំផ្ទីគ្រាប់ឲ្យដុះលូតលាស់ល្អគួរដាំមុនការបញ្ចប់នៃរដូវភ្លៀងទាំងស្រុងដោយហេតុនេះការប្រមូតកាត់នឹងធ្វើឡើងយ៉ាងតិច ២ទៅ៤សប្តាហ៏បន្ទាប់ពីរដូវភ្លៀងត្រូវបានបញ្ចប់។ ជាទូទៅនៅភាគខាងជើងនៃខ្សែអេក្វាទ័រ ការដាំដុះអាចដាំនៅពេលណាមួយក្នុងកំឡុងខែកញ្ញា ឬខែតុលា។ ចំពោះតំបន់ខ្ពង់រាបនៃភូមិភាគអាស៊ីអាគ្នេយ៍បើទោះជាការដាំសំរាប់ផលិតយកស្លឹករបស់វាក៏អាចដាំនៅពេលណាក៏បានឲ្យតែដីមានសំណើមគ្រាប់គ្រាន់។

## ការពិនិត្យពិច័យផ្សេងទៀត

*ទំហំគ្រាប់តូច ការដាំគ្រាប់ រង្វើល ញឹក និងចន្លោះជួរៈ* ផ្ទីគ្រាប់ គឺមាន ទំហំតូចណាស់ នេះមានន័យថា ពេលណាកសិករដាក់គ្រាប់ដាំវាក្រាស់ឬញឹកពេកធ្វើឲ្យការដុះលូតលាស់មិនល្អ។ ដូច្នេះត្រូវដាក់គ្រាប់ដាំឲ្យរង្វើលបន្តិច ហើយធ្វើយ៉ាងណាឲ្យមានចន្លោះពីដើមមួយទៅដើមមួយ ប្រវែង ១៥សង់ទីម៉ែត្រក្នុងជួរ។ ប្រសិនដំណាំដុះញឹកច្រើនពេក ធ្វើឲ្យដើមតូចស្តើងទាំងអស់ហើយ នឹងផលិតគ្រាប់តូចបំផុត។ ចន្លោះពីជួរមួយទៅជួរមួយទៀតមានប្រវែង ៦០សង់ទីម៉ែត្រអាចធ្វើឲ្យ ដំណាំដុះលូតលាស់ល្អរឹងមាំ និងមិនលូតខ្ពស់ពេក ដែលនឹងបណ្តាលឲ្យបាក់ដើមនៅពេលមាន ខ្យល់ខ្លាំង។ ដើម្បីបន្ថយចំនួនដើមឲ្យរង្វើលទៅតាមអ្វីដែលយើងត្រូវការនោះពេលដាំត្រូវយកគ្រាប់ ពូជលាយជាមួយខ្សាច់ស្ងួត ហើយទុកចន្លោះ ១៥ សង់ទីម៉ែត្រពីដើមមួយទៅមួយ។

*សត្វល្អិតចង្រៃៈ* ការពិសោធន៍នៅឈៀងម៉ៃ ប្រទេសថៃបញ្ជាក់ថា សត្វល្អិត Lygus (អណ្តើកមាស) បានបំផ្លាញដំណាំផ្ទីគ្រាប់នៅពេលដែលវាចាប់ចេញផ្កា។ ទោះបីយ៉ាងណា អណ្តើកមាស នេះត្រូវបានកំចាត់ដោយប្រើថ្នាំសំលាប់សត្វល្អិត ដែលមានជាតិពុលទាបយកល្អ ប្រើថ្នាំផ្សំពីធម្មជាតិ។ ដង្កូវស៊ីរូងដើមក៏ជាបញ្ហាមួយក្នុងការបំផ្លាញដំណាំនេះខ្លះដែរ។

*ការប្រើប្រាស់ដំណាំផ្ទីគ្រាប់ឲ្យបានជាប្រយោជន៍ៈ* វេជ្ជបណ្ឌិត Chuckree Senthong នៅ មហាវិទ្យាល័យឈៀងម៉ៃ បានជ្រើសរើសប្រភេទពូជផ្ទីគ្រាប់ដែលស៊ាំយ៉ាងល្អ ក្នុងកំឡុងពេល ពិសោធន៍ក្នុងទសវត្សរ៏ទី ៨០។ គាត់កំពុងចាប់ផ្តើមផលិតប្រភេទពូជទាំងនេះ ដែលអាចនឹងមាន ជោគជ័យច្រើន។ ពូជនេះនឹងមានការពិសោធន៍ដោយកសិករ ហើយត្រូវបាននាំចូលពីអាហ្វ្រិក ខាងកើត។

## មេរៀនពី បទពិសោធន៏របស់ CRWRC នៅអាហ្វ្រិកខាងកើត

អ្នកធ្វើការខាងអភិវឌ្ឍន៏ដែលកំពុងគិតគូរចង់លើកកំពស់ដំណាំផ្ទីគ្រាប់ឲ្យទៅជាដំណាំជាតិ ថ្មី មួយនៅអាស៊ី អាចនឹងចាប់អារម្មណ៏ ពីបទពិសោធន៏ នៃការខិតខំប្រឹងប្រែងរយៈពេល ១០ឆ្នាំ របស់ **CRWRC** នៅ អាហ្វ្រិកខាងកើត។

បទពិសោធន៏ទាំងនោះមានដូចខាងក្រោមៈ

- ជាដំណាំមួយប្រភេទ ដែលកសិករមិនធ្លាប់ស្គាល់ ហើយត្រូវការពេលវេលាច្រើនដើម្បីបង្ហាត់បង្ហាញ និងតាមដាន។ CRWRC បានសិក្សាឃើញដោយឲ្យគ្រួសារកសិករ ដែលស្ម័គ្រចិត្តធ្វើការផ្តល់យោបល់ពីជីវជាតិរបស់ធញ្ញជាតិនោះទៅដល់កសិករផ្សេងៗ គឺជាវិធីសាស្ត្រមួយ ដែលអាចជួយបានច្រើន។
- ចាប់ផ្តើមការបង្រៀនដោយឲ្យប្រជាជនភ្លក់រស់ជាតិដំណាំថ្មីនេះជាមុនសិន (ដោយលាយគ្រាប់ផ្ទីជាមួយទឹង ធញ្ញជាតិផ្សេងទៀតដូចជា អង្ករ ឬពោត ក្នុងកំរិត ១ភាគ ពីរ ១ភាគ ៤ ឬ១ភាគ៥)។ ហើយប្រសិនបើ ប្រជាជនប្រើម្សៅគ្រាប់ផ្ទីនេះ គួរបង្រៀនប្រជាជនឲ្យប្រើពី ២ ទៅ ៣ស្លាបព្រាបាយក្នុង ១ថ្ងៃ សំរាប់កុមារ និងប្រហែល ៤ស្លាបព្រាបាយក្នុង ១ថ្ងៃ សំរាប់មនុស្សពេញវ័យ។
- រៀបចំឲ្យមាន "ការធ្វើបង្ហាញពីរបៀបទទួលទាន "និងអាចជួយបង្កើនការប្រើប្រាស់ដំណាំផ្ទីគ្រាប់នៅតាមផ្ទះ។
- ការលាយផ្ទីគ្រាប់ ជាមួយនឹងអាហារប្រពៃណីជាវិធីដ៏ល្អ និងអាចបង្កើនការ ទទួលយកពីប្រជាជន។
- ចាប់ផ្តើមពីការដាំដំណាំផ្ទីគ្រាប់សំរាប់ធ្វើជាអាហារ និងសូមកុំធ្វើការសន្យាថា អ្នកនឹងផ្តល់ទីផ្សារសំរាប់លក់ដំណាំនេះទៅកាន់ពួកគេ។
- កុំធ្វើការសន្មតថា អ្នកមានពូជដែលល្អបំផុត។ ព្រោះពូជទាំងអស់ គឺមានការខុសគ្នាទៅតាមតំបន់ដាំដុះ (រស់ជាតិ និងផលិតភាពរបស់វា)។
- ជាទូទៅយុវជនដែលមានផ្ទុក HIV ប្រាប់ថាសុខភាពរបស់គេបានប្រសើរឡើងក្រោយពេលពួកគេបានទទួលទានផ្ទីគ្រាប់នេះ។ ដូចគ្នាផងដែរចំពោះក្មេង ដែលខ្វះជីវជាតិក៏បង្ហាញនូវការកើនទំងន់ក្រោយពេលពួកគេបានទទួលទានដំណាំនេះ ។
- ប្រជាជនអាចហូប និងលក់ទាំងស្លឹក និងគ្រាប់បាន។
- កសិករបានធ្វើការសាកល្បងឃើញថា ដំណាំនេះអាចធន់នឹងអាកាសធាតុរាំងស្ងួតបាន។
- បើទោះជាដំណាំពោតមិនអំណោយផលក៏កសិករនៅតំបន់អាកាសធាតុសើមស្ងួត នៅតែអាចប្រមូលផល ពីដំណាំផ្ទីគ្រាប់នេះបានដែរ។

**របាយការណ៍ពីដំណាំផ្លីគ្រាប់នៅអាហ្វ្រិកខាងកើតស្តីពីអត្ថប្រយោជន៍នៃដំណាំនេះទៅលើជីវជាតិ សុខភាព និងការដាំដុះមានដូចជា**

- ម្តាយរាយការណ៍ថាកូនៗរបស់គាត់មានភាពវៃឆ្លាត នៅសាលារៀនតួយ៉ាង ដូចជាពួកគេមានភាពវាងវៃច្រើនបន្ទាប់ពី ទទួលទានអាហារដែលមានជីវជាតិ។
- ការចុះទៅសង្កេតមើលជាបន្តបន្ទាប់បានបង្ហាញឲ្យឃើញថាកុមារមានស្បែកភ្លឺរលោងជាងមុនដោយទ្បែកមានភាពស្ងួតតិចតួច និងស្បែកដៃរបកក៏តិចតួចដែរ។
- កុមារអាយុក្រោម ៥ឆ្នាំមានការលូតលាស់ជាធម្មតា បន្ទាប់ពីពួកគេទទួលទានផ្លីគ្រាប់នេះរាល់ថ្ងៃ។ព្រោះតែ លទ្ធផលទទួលបានដ៏អស្ចារ្យនេះ ធ្វើឲ្យនៅក្នុងសហគមន៍គិលានុប្បដ្ឋាយិកា និងនៅតាមគ្លីនិក បានធ្វើការណែនាំដល់ស្ត្រីជាម្តាយឲ្យគាត់បញ្ចុកអាហារផ្លីគ្រាប់នេះដល់កូនៗរបស់គាត់ដែលខ្វះសារធាតុចិញ្ចឹម និងការលូតលាស់មិនគ្រប់ទំងន់
- អ្នកធ្វើការងារខាងសុខភាពនិងស្ត្រីជាម្តាយបានរៀបរាប់ប្រាប់យើងជាច្រើនលើកច្រើនសារថា ក្រោយពីបរិភោគអាហារផ្លីគ្រាប់នេះធ្វើឲ្យជំងឺខ្វះឈាមលើស្ត្រីជាម្តាយមានការថយចុះ (នៅក្នុងដំណាំនេះ មានកំរិតជាតិដែកខ្ពស់)
- យើងក៏ទទួលបានពត៌មានផងដែរពីស្ត្រីដែលជាម្តាយដែលមានការខ្វះទឹកដោះគាត់ប្រាប់ថាទឹកដោះរបស់គាត់មានការកើនឡើងគួរឲ្យកត់សំគាល់នៅពេលគាត់បានទទួលទានអាហារដែលផ្សំពីផ្លីគ្រាប់នេះ។
- ចំពោះអ្នកផ្ទុកមេរោគអេដស៍បាននិយាយថា ថ្នាំ ARV មិនបានធ្វើឲ្យឈឺចាប់ទេ។
- យើងបានឮជាច្រើនលើកច្រើនសារថា អ្នកផ្ទុកមេរោគអេដស៍ ដែលបានប្រើប្រាស់គ្រាប់ផ្លីនេះអាចបង្កើនន្ទូវចំនួន CD-4 រហូតដល់ទៅរាប់រយ។ ពួកគេអាចចាប់ផ្តើមប្រើប្រាស់ថ្នាំ ARV បន្ទាប់ពីចំនួន CD កើនពី 600 ឡើងទៅ។
- យើងក៏ទទួលបានពត៌មានដែរថា អ្នកដែលមានជំងឺសន្លាក់ដៃជើង និងអ្នកមានបញ្ហាត្រគាកមានភាពធូរស្រាលឡើងច្រើនបន្ទាប់ពីបានប្រើប្រាស់ធញ្ញជាតិនេះ។
- កុមារមានភាពវៃឆ្លាតច្រើននៅសាលារៀននិងចំពោះមនុស្សពេញវ័យមានកំលាំងខ្លាំងក្លា។

- គ្រាប់ធញ្ញជាតិនេះ គឺជាជំនួយដ៏សំខាន់ចំពោះអ្នកមានរោគទឹកនោមផ្អែម ដែលត្រូវតមអាហារ។
- គេបានប្រាប់យើងផងដែរថា សត្វគោដែលបានស៊ីដើមធញ្ញជាតិនេះមានទឹកដោះច្រើន។
- ចំពោះមាន់ ដែលបានស៊ីសំបកធញ្ញជាតិនេះ អាចធ្វើឲ្យចំនួនពងកើនឡើងទ្វេដង ហើយសំបកពងមាន់ក៏រឹងជាងមុនផងដែរ។
- ពេលនេះតំរូវការលើទីផ្សារនៃធញ្ញជាតិនេះមានហើយ។ផ្សារបានទិញគ្រាប់ធញ្ញជាតិនេះពីអ្នកកិនស្រូវផងដែរ។ នៅ Kampala ប្រទេស Uganda ធញ្ញជាតិនេះត្រូវបានគេប្រើវានៅក្នុងអាហារពោត (ម្សៅពោត) ជំនួសសារធាតុ លីស៊ីន ដែលចំរាញ់ចេញពីសណ្តែកសៀង ដែលពីមុននេះត្រូវបានគេនាំចូលពីអាហ្វ្រិកខាងត្បូង។
- គ្រួសារជាច្រើនកំពុងតែទទួលយកការដាំដុះធញ្ញជាតិនេះព្រមទាំងប្រើប្រាស់វាប្រចាំគ្រួសារផងដែរ។

## ជំហានផ្សេងៗក្នុងការផ្សព្វផ្សាយនៅអាហ្វ្រិកខាងកើតមានដូចតទៅ

- **ការបញ្ចាំងវីដេអូ:** វីដេអូស្តីពីធញ្ញជាតិថ្មីគ្រាប់របស់ CRWRC ត្រូវបានបញ្ចាំងជូនបុគ្គលិកនៃអង្គការដៃគូឲ្យបានឃើញ តាមរយៈកុំព្យូទ័រក្នុងការិយាល័យ នៅក្នុងតំបន់របស់ពួកគេ។
- **ផ្តល់នូវការជជែកអំពីអាហារូបត្ថម្ភ:** ការជជែកអំពីអាហារូបត្ថម្ភត្រូវបានធ្វើឡើងនៅតាមភូមិ ដែលនៅក្នុងពេលនោះ រឿងរបស់ធញ្ញជាតិថ្មីគ្រាប់នេះក៏ត្រូវបានអ្នកភូមិដទៃទៀតនិយាយប្រាប់។ ការសម្របសម្រួលទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍រវាងភូមិថ្មីៗ និងភូមិ ដែលធ្លាប់មានបទពិសោធន៍ជាមួយ នឹងធញ្ញជាតិនេះជាវិធីសាស្ត្រដ៏ប្រសើរមួយ ហើយបើ



អាចទៅរួចគួរតែអញ្ជើញបុគ្គលិកក្រសួងកសិកម្មទៅជាមួយផង។

- **ត្រូវចងចាំថាគួរតែអញ្ជើញស្ត្រីមកផង:** ការរៀនចំអិនធញ្ញជាតិ ថ្មីគ្រាប់នេះជារឿងសំខាន់
- **ចំណុចបញ្ជាក់ទាំងនេះមាន**
  - ដំបូងគួរតែបញ្ជាក់ពីគុណប្រយោជន៍ ខាងអាហារូបត្ថម្ភជាមុនសិន ដូចជាធ្វើឲ្យកុមារមានភាពរាងរៃឡើងជួយរក្សាតុល្យភាព នៃការតមអាហាររបស់អ្នកមានជំងឺទឹកនោមផ្អែមជាដើម។
  - បន្ទាប់មកទៀតអត្ថប្រយោជន៍ សំរាប់អ្នកផ្ទុកមេរោគអេដស៍ គួរតែបញ្ជាក់ប្រាប់បន្ទាប់ពីបង្ហាញពីគុណប្រយោជន៍ ខាងអាហារូបត្ថម្ភ។ យើងយល់ឃើញថា បើយើងបញ្ជាក់អំពីអត្ថប្រយោជន៍ សំរាប់អ្នកផ្ទុកមេរោគអេដស៍មុននោះ វានឹងធ្វើឲ្យមានឥទ្ធិពលមិនល្អក្នុងការដាំធញ្ញជាតិនេះ។
  - គួរបញ្ជាក់ផងដែរ អំពីការិតនៃការលាយឲ្យបានត្រឹមត្រូវ ចំពោះការលាយគ្រាប់ធញ្ញជាតិនេះ ជាមួយនឹងធញ្ញជាតិចំបងរបស់គាត់ផ្សេងទៀតដូចជាអង្ករ ឬពោត។
- បង្ហាញពីការដាំធញ្ញជាតិនេះលើដីពីរកន្លែង: មួយសំរាប់យកស្លឹកធ្វើជាអាហារ និងមួយទៀតសំរាប់យកគ្រាប់ធ្វើជាអាហារ។
- ត្រូវប្រាកដថាដីដាំបង្ហាញនោះគួរជ្រើសរើសនៅកន្លែងដែលមានមនុស្សទៅមកច្រើនដូចជានៅមន្ទីរពេទ្យ សាលារៀន រឺ ព្រះវិហារព្រោះជាកន្លែង ដែលមនុស្សងាយនឹងមើលឃើញ និងរៀនសូត្របាន។
- បើដាំដីជិតផ្ទះគួរជ្រើសរើសចំណុចដាំ ចំងាយ១០ម៉ែត្រពីផ្ទះជាដី ដែលមានដីជាតិល្អ ហើយអ្នកផ្ទះងាយនឹងទៅមើល។
- កំណត់ពេលដាំដុះឲ្យបានត្រឹមត្រូវសំរាប់អាហ្វ្រិកខាងកើត ការដាំដុះធញ្ញជាតិនេះធ្វើឡើងបន្ទាប់ពីភ្លៀងចាប់ផ្ដើមធ្លាក់ ព្រោះវាជាតំបន់ដែលរដូវភ្លៀងមានរយៈពេលខ្លី (គឺអាកាសធាតុ ខុសឆ្ងាយពីតំបន់អាស៊ីអាគ្នេយ៍)។ ការដកឲ្យដើមរធ្មើល និងការដកស្មៅឲ្យបានទៀងទាត់អាចផ្ដល់នូវលទ្ធផលល្អ។

- បង្កើនគ្រាប់ពូជដោយបង្រៀនកសិករឲ្យដាំធញ្ញជាតិដែលរឹងមាំនិងមានសុខភាពល្អជាមុន ហើយធ្វើការសន្សំពូជទុកសំរាប់ការដាំដុះនៅពេលក្រោយទៀត។
- **បរិភោគអាហារ ថ្មីគ្រាប់ ទាំងអស់គ្នា!**

## ការតាមដានគឺជាចំនុចសំខាន់!

- នៅអាហ្វ្រិកខាងកើត ក្នុងមួយរដូវដាំដុះគេត្រូវការចុះទៅតាមដានចំនួន ២ដង។ លើកទីមួយធ្វើឡើងនៅសប្តាហ៏ទី៤ នៅរដូវដាំដុះ។ យើងធ្វើការលើកទឹកចិត្តដល់បុគ្គលិកមូលដ្ឋានរបស់អង្គការជាដៃគូរឲ្យចុះទៅមើលផងដែរនៅពេល ដកដើមឲ្យរង្វើល (លើកទី១ និងទី២) ហើយ បន្ទាប់មកទៀតគឺទៅមើលនៅពេលប្រមូលផល។
- ការចុះទៅមើលផ្លាស់ប្តូរបទពិសោធន៏ ពីកសិករទៅកសិករ ពីបុគ្គលិកទៅបុគ្គលិកជាវិធីសាស្រ្តដ៏មានប្រសិទ្ធភាព
- ការដាំបង្ហាញនៅឯមន្ទីរពេទ្យ និងនៅក្នុងសួនក៏ជាវិធីសាស្រ្ត ដ៏មានប្រសិទ្ធភាពដែរ។ ជាលទ្ធផលបុគ្គលិកមន្ទីរពេទ្យ នឹងក្លាយទៅជាអ្នកផ្សព្វផ្សាយដ៏សំខាន់។

*(អ្នកកែសំរួល:* បន្ថែមពីលើបទពិសោធន៏ដ៏អស្ចារ្យក្នុងការលើកកំពស់ផ្សព្វផ្សាយដំណាំថ្មីគ្រាប់នៅអាហ្វ្រិកខាងកើត TomPost ក៏បានធ្វើការសាកល្បងធម្មតាមួយដោយដាំដុះដំណាំនេះនៅលើដីក្នុងខេត្តឈៀងម៉ៃ ប្រទេសថៃ។ បើសិនជាមានសំនួរទាក់ទងនឹងការផ្សព្វផ្សាយដំណាំនេះសូមទាក់ទងមក Tom *តាមរយ: postt@crcna.org.* លើសពីនេះទៀត *Dr.Chuckree Senthong* កំពុងតែបន្តសាកល្បង ដាំពិសោធន៏ពូជនេះ នៅឯសកលវិទ្យាល័យឈៀងម៉ៃ ហើយអ្នកទាក់ទងទៅគាត់បានតាមរយ: *agicsnth@chiangmai.ac.th)*

បើចង់បានពត៌មានបន្ថែមស្តីអំពីធញ្ញជាតិនេះ អ្នកអានអាចរកមើលនៅក្នុង *EDN Issue 91 (April2006) http://www.echotech.org/mambo/index.php?option=com_docman&task=cat_view&gid=13&dir=DESC&order=name&limit=10&limitstart=10.*

## ឯកសារយោង

Ray Heinicke, e-mail message to the editor, March 27, 2009.

# ការដាំដុះនៅអាស៊ីៈ ដំណាំដែលគេមិនសូវស្គាល់

## ដំណាំម៉ាក់ប្រាំង (Marian Plum)



ម៉ាក់ប្រាំងជាដំណាំឈើហូបផ្លែ ដែលពេលទុំវាមានពណ៌លឿង ឬទឹកមាសហាក់ដូចជាបញ្ចាញពន្លឺចែងចាំង ក្នុងស្លឹកឈើ ពណ៌បៃតងរបស់វា។ ផ្លែម៉ាក់ប្រាំងទុំ មានសំបកស្រួយ និងសាច់ពណ៌លឿងទុំ ដ៏មានឱជារសសំរាប់បរិភោគ។ ក្រៅពី បរិភោគជាបផ្អែមហើយម៉ាក់ប្រាំង ក៏ត្រូវបានគេយកទៅកែច្នៃលាយបញ្ចូលជាមួយគ្រឿងផ្សំ និងធ្វើជាដំណាប់ ដូចជាស្វាយដែរ។

ម៉ាក់ប្រាំងមានដើមកំណើតចេញពីឧបទ្វីបម៉ាឡេស៊ី ភាគខាងជើងស៊ូម៉ាត្រា និងកោះជ្វា។ យោងទៅតាមមជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក វាត្រូវបានគេស្គាល់ថា ហ្កាន់ដារីយ៉ា នៅប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី រីឯរ៉ិមប៊ូនីយ៉ា នៅប្រទេសម៉ាឡេស៊ី។ ចំណែកក្នុងប្រទេសថៃវិញគេឲ្យឈ្មោះ ថាម៉ាក់ប្រាំង។ ម៉ាក់ប្រាំងជារុក្ខជាតិមួយប្រភេទនៃគ្រួសារ (Anacardiaceae) សណ្ឋាននិងឱជារសដូចទៅនឹងស្វាយ។ ជាទូទៅម៉ាក់ប្រាំងត្រូវបានដាំពីគ្រាប់។ ទោះបីយ៉ាងណាក៏យើងអាចបង្កើនចំនួនកូនឈើម៉ាក់ប្រាំងទៅតាមអ្វី ដែលយើងចង់បានដោយប្រើវិធីសាក ឬបំបៅដែរ។ រុក្ខជាតិនេះលូតលាស់ល្អនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់និងដីមានជីជាតិ។ បើដាំដោយកូន (សាកឬបំបៅ) វាផ្តល់ផ្លែ ចាប់ពីអាយុ ៥-៦ឆ្នាំ ប៉ុន្តែបើដាំដោយគ្រាប់អាចផ្តល់ផ្លែចាប់ពីអាយុ ៨-១០ ឆ្នាំ (ICRAF)។ នៅប្រទេសឥណ្ឌូណេស៊ី ម៉ាក់ប្រាំងចេញផ្កាចន្លោះខែមិថុនាដល់ខែវិច្ឆិកា ហើយឲ្យផ្លែពីខែមិនា ដល់ខែមិថុនា។ មិនដូចជានៅប្រទេសថៃ ចេញផ្កាខែវិច្ឆិកាដល់ខែធ្នូ ហើយផ្លែពីខែមិនា ដល់ឧសភា វិញ **(អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ)**។ ប្រភេទមួយចំនួនរបស់ម៉ាក់ប្រាំង ត្រូវបានបែកចេញទៅតាមឱជារសផ្អែម និងជូរ។ ផ្លែផ្អែមត្រូវបានគេយកទៅលក់នៅទីផ្សាររីឯប្រភេទខ្លះមានឱជារសមិនសូវផ្អែម។ ប្រភេទម៉ាក់ប្រាំង

ថៃផ្សេងទៀតត្រូវបានគេស្គាល់ថា ម៉ាក់យុង ឬខ្មែរហៅថា ម៉ាក់ព្រាង គឺដូចគ្នាទៅនឹងម៉ាក់ប្រាំង គ្រាន់តែពេលទុំមានឱជារសជូរ។

ម៉ាក់ប្រាំង គេច្រើននិយមដាំសំរាប់បេះយកផ្លែ និងជាដើមឈើយកម្លប់ក្នុងសួនដំណាំ។ ប៉ុន្តែតាមសេចក្តីរាយការណ៍របស់ FAO ថានៅដើមឆ្នាំ ១៩៩០ ការអភិវឌ្ឍន៍ពាណិជ្ជកម្ម នៃដំណាំ ម៉ាក់ប្រាំងត្រូវគេរកឃើញមានជាច្រើនខេត្តក្នុងប្រទេសថៃ ជាមួយកសិផល ជាមធ្យម ៧០០០គីឡូក្រាមក្នុង ១ហិចតា និងត្រូវបានគេលក់នៅតាមតូបផ្សារក្នុងភូមិរហូតដល់ផ្សារទំនើប (Supermarket)។ តាមការឲ្យដឹងថារាជរដ្ឋាភិបាលថៃ ក៏កំពុងផ្សព្វផ្សាយពីការនាំចេញកសិផល ម៉ាក់ប្រាំងផងដែរ។ ម៉ាក់ប្រាំងត្រូវបានគេដាំនិងស្គាល់យ៉ាងទូលំទូលាយជាពិសេសនៅអាស៊ីអាគ្នេយ៍ ត្រូវបានគេចាប់អារម្មណ៍កាន់តែច្រើន។

## ឯកសារយោង


ឯកសារពី Agroforestry Tree Database: ការណែនាំពីការជ្រើសរើស និងសេចក្តីបញ្ជាក់ ពីប្រភេទដើមឈើ "Bouea macrophylla." មជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក http://www.worldagroforestrycentre.org/Sea/Products/AFDbases/AF/asp/SpeciesInfo.asp?SpID=18075.

កន្លែងទុកដាក់ឯកសាររបស់អង្គការ FAO "ឈើហូបផ្លែនៃតំបន់ត្រូពិច ដែលមិនបានប្រើប្រាស់ជាប្រយោជន៍ក្នុងប្រទេសថៃ *ភាគ១*, ពូជជាមួយសក្តានុពលសំរាប់វឌ្ឍនកម្មពាណិជ្ជកម្ម, 3. ម៉ាក់ប្រាំង (Bouea macrophylla Griff.)." ការិយាល័យតំបន់សំរាប់អាស៊ី និងអាស៊ីប៉ាស៊ីភិច http://www.fao.org/docrep/004/ab777e/ab777e04.htm.

Morton, Julia F. *Fruits of Warm Climates*. Miami: Published by Julia F. Morton. 1987.

# ស្ថានភាពស្បៀងពិភពលោក៖

## តើព្យុះដ៏ធំបំផុតនេះបន្តផ្លាស់ទីដើម្បីប្រែក្លាយជាពពកដែលរសាត់  តែប៉ុណ្ណោះឬ?

**រៀបរៀងដោយ បណ្ឌិត Jim Goering**

**បុព្វកថាដោយ Rick Burnette**

Jim Goering គឺជាក្រុមប្រឹក្សាមួយរបស់ ECHO និងជាបណ្ឌិតសេដ្ឋកិច្ចកសិកម្ម ហើយមានបទពិសោធន៍ការងារនៅឯមហាវិទ្យាល័យកាលីហ្វរញ៉ា ទីក្រុងបេក្លី (the University of California /Berkeley), មហាវិទ្យាល័យហាវឺដ (Harvard University), ធនាគារពិភពលោក (World Bank) ហើយនិងនៅអង្គការស្បៀងអាហារពិភពលោក (World Vision)។ ក្នុងសេចក្តីថ្លែងការមួយនៃសន្និសិទកសិកម្ម ECHO 2008 លោកបណ្ឌិត Goering បានលើកឡើងអំពីករណីដែលបណ្តាលឲ្យមានការកើនឡើងយ៉ាងឆាប់រហ័សនូវតំលៃស្បៀងពិភពលោកចន្លោះឆ្នាំ ២០០៦ ដល់ ២០០៨ បើប្រៀបធៀបទៅ ៤ទសវត្សរ៍មុន ក្រោយទាំងការចុះ និងភាពនឹងនៃតំលៃស្បៀង។

កត្តាដែលនាំឲ្យការផ្គត់ផ្គង់ស្បៀងចុះថយ មកពីតំលៃប្រេងឥន្ទនៈឡើងថ្លៃខ្ពស់ ធញ្ញជាតិ និងរុក្ខជាតិ ដែលដាំយកគ្រាប់ធ្វើប្រេងត្រូវបានកែច្នៃជាជីវឥន្ទនៈវិញ។ អាកាសធាតុពិភពលោកមិនអនុគ្រោះដល់ដំណាំកសិកម្ម ហើយនិងការធ្លាក់ចុះយ៉ាងលឿន ក្នុងការបណ្តាក់ទុនផ្នែកសាធារណៈខាងវិស័យកសិកម្ម ក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូចគ្នាដែរការរីកចំរើននៃចំនួលក្នុងទីក្រុងនៅប្រទេសឥណ្ឌា និងចិនការបរិភោគសាច់មានការកើនឡើងក្នុងរដ្ឋមួយចំនួន ហើយដោយសារចំនួនប្រជាជនពិភព លោកចេះតែបន្តកើនឡើង ធ្វើឲ្យតម្រូវការស្បៀងក៏ត្រូវបានបង្កើនដែរ។ យោងតាមសម្តី បណ្ឌិត Goering ទោះជាព្យុះដ៏ធំបំផុតនេះ បានរាលដាលពាសពេញពិភពលោកយ៉ាងលឿនដល់ចំនុចកំពូលចំពោះតំលៃធញ្ញជាតិ និងស្បៀងក៏ដោយក៏សេដ្ឋកិច្ចពិភពលោក នៅតែធ្វើឲ្យយ៉ាប់យឺនដដែល ជាលទ្ធផលបានពីការចាប់ផ្តើមធ្លាក់ចុះនូវតំលៃធញ្ញជាតិ និងស្បៀងវិញ

នៅចុងពាក់កណ្តាលឆ្នាំ ២០០៨ដែលជាដើមហេតុនៃភាពរសាត់អណ្តែតតំលៃស្បៀងបច្ចុប្បន្ន។ តើទៅថ្ងៃអានាគតគួរតែធ្វើអ្វី?

## ទស្សនវិស័យ

អ្វីជាទស្សនវិស័យសំរាប់តំលៃស្បៀងនៅលើពិភពលោក? នៅពេលអនាគតដ៏ខ្លី (ពីរ ឬបីខែបន្ទាប់) ការធ្វើឲ្យមានលំនឹងខ្លះ ចំពោះតំលៃស្បៀងសកលហាក់ដូចជាត្រឹមត្រូវក្នុងការឆ្លើយតបទៅដល់ការថយចុះនាពេលថ្មីៗនេះតែម្តងនូវតំលៃធញ្ញជាតិ និងថាមពលនៅលើពិភពលោក។ ក្នុងរយះពេលខ្លី (២ឬ៣ឆ្នាំបន្ទាប់ទៀត) តំលៃស្បៀងពិភពលោក ប្រហែលជានៅតែខ្ពស់ដដែលដោយសារមូលហេតុឃ្លាំងធញ្ញជាតិដែលចុះថយនូវបរិមាណស្តុកទុកត្រូវបានគេបំពេញវិញ។ ការកើនឡើងសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅតែបន្តក្នុងបណ្តាប្រទេសមួយចំនួន ដូចជា ចិន និងឥណ្ឌា ហើយតំលៃសំភារៈសំរាប់ប្រើប្រាស់ក្នុងកសិដ្ឋានដូចជា ជីនៅមានតំលៃថ្លៃ ប្រហែលជាក្រោយឆ្នាំ ២០១០ ទស្សនវិស័យប្រែក្លាយជាមិនច្បាស់លាស់ច្រើនឡើង។។ ក្នុងកំឡុងពេលនោះកសិករនៅលើពិភពលោកទំនងជាឆ្លើយតបជាមួយនឹងកសិផល ដែលត្រូវបានបង្កើនឡើង ព្រោះតែតំលៃឡើងខ្ពស់របស់ធញ្ញជាតិ។ ទោះជាយ៉ាងណាក៏ពួកយើង ទំនងជាយល់ច្បាស់ពីការបន្តកើនឡើងនូវប្រាក់ចំណូល ហើយពេញពិភពលោកមានការប្រែប្រួលដែលទាក់ទងអាហារបរិភោគប្រចាំថ្ងៃ។ តំលៃថាមពល និងសំភារៈប្រើប្រាស់សំរាប់កសិដ្ឋានបន្តឡើងតំលៃខ្ពស់ ហើយកំនើនប្រជាជនស្ថិតនៅនឹង។ ដោយមានតថភាពទាំងនោះតំលៃធញ្ញជាតិ និងស្បៀងពិភពលោកគឺទំនងជានៅមានសារៈសំខាន់ពីលើកំរិតនៃ ២ទសវត្សរ៍កន្លងទៅ។

ប្រហែលជាពិតមែន ប្រសិនបើតំលៃស្បៀងត្រូវបានគេធ្វើឲ្យមានលំនឹងពីកំរិតខ្ពស់នៅឆ្នាំ ២០០៦ ដល់ ២០០៧នោះសង្គមគឺត្រូវបានផ្គត់ផ្គង់គ្រប់គ្រាន់។ ប្រសិនវាកើតឡើងមែនការឆ្លើយតបដ៏សមរម្យមួយ ពីសហគមន៏អន្តរជាតិនឹងត្រូវបានស្នើសុំឡើង។ ក្នុងកំឡុងពេលនេះនឹងមានតម្រូវការចាំបាច់សំរាប់ការផ្គត់ផ្គង់ស្បៀងត្រូវបានបង្កើនឡើង ដើម្បីប្រើជាជំនួយមនុស្សធម ក្នុងស្ថានភាពស្បៀងបន្ទាន់ ដូចជា Darfur ហើយនិងប្រទេសដែលជួបភាពរាំងស្ងួតមានរយះពេលយូរ ដូចជា Ethiopia ។ ការទន្ទឹង រង់ចាំនូវតម្រូវការចាំបាច់ ដើម្បីបង្កើននិងផ្តល់ភាពសំខាន់សារជាថ្មី

ចំពោះការវិនិយោគផ្នែកកសិកម្ម ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាមួយនិងចំនុចរួមលើកសិករ ដែលមានដីតិច ហើយលើការស្រាវជ្រាវកសិកម្មក្នុងទិសដៅដើម្បីពង្រឹងបច្ចេកវិជ្ជាកសិកម្ម សំរាប់រយៈពេលយូរអង្វែង។ អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិបានធ្វើការប្រមាណថា តំលៃប្រចាំឆ្នាំនៃកម្មវិធីដ៏ទូលំទូលាយមួយ ដែលទាក់ទងនឹងជម្មជាតិនេះគឺប្រហែលជា ៣០ពាន់លានដុល្លារ ក្នុងមួយឆ្នាំ ដែលចំនួនទឹកប្រាក់នេះល្មមនឹងចាត់ចែងបាន ប្រសិនបើមានការគាំទ្រផ្នែកនយោបាយជុំវិញពិភពលោកចំពោះការទំព្រឹងប្រែង។

ចំពោះទស្សនៈរបស់ក្រសួង-ECHO

បានលើកឡើងជាយោបល់សំរាប់ពិចារណាដូចខាងក្រោម:

១. ចក្ខុវិស័យរបស់ ECHO ជំរុញការទំព្រឹងប្រែងរបស់ពួកយើង ដើម្បីនាំមកនូវភាពរុងរឿងទៅកាន់ព្រះជាម្ចាស់ ហើយព្រះនឹងប្រសិទ្ធិពរដល់មនុស្សជាតិដោយប្រើវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជាដើម្បីជួយជនក្រីក្រ។

២. គោលដៅរួមត្រូវបានបន្តលើប្រជាជនក្រីក្រជាកសិករដែលគ្មានដីសំរាប់ប្រកបរបរកសិកម្ម ទ្រព្យសេដ្ឋកិច្ចបន្តិចបន្តួចជនជាតិភាគតិច ។ល។

៣. ការសំខាន់ផ្តោតលើសកម្មភាពអភិវឌ្ឍន៍ ចំពោះប្រជាជនក្រីក្រ ដូចជាកសិករតូចតាចក្នុងតំបន់ដែលមានដីស្ទើរតែគ្មានតំលៃសំរាប់ធ្វើកសិកម្ម។

៤. ការស្រាវជ្រាវត្រូវបន្តសំរាប់បច្ចេកវិជ្ជាបង្កើនផលិតផលស្បៀងកំរិតក្នុងស្រុក ហើយផលិតផល ដែលសល់ពីតំរូវការអាចលក់បានជាមួយការប្រើតិចបំផុត នៃសារធាតុសំរាប់ប្រើក្នុងកសិដ្ឋាន ដែលបានទិញពីទីផ្សារ។

៥. ការសំខាន់ផ្តោតលើឱកាសដ៏មានប្រសិទ្ធិភាព ចំពោះតំលៃទៅលើការរីកឡើង នៃកម្មវិធីគំរោងក្នុងតំបន់ ដែលខ្វះខាតស្បៀងដ៏រ៉ាំរ៉ៃ ដូចជានៅទ្វីបអាហ្វ្រិចផ្នែកខាងក្រោមតំបន់សាហារ៉ា

៦. ការស្រាវជ្រាវត្រូវបន្តទាក់ទងទៅ និងកម្មវិធីមួយចំនួន ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការមួយចំនួនទៀតដូចជា World Vision, Gates Foundation, CGIAR ហើយ និង US Peace Corps ។

ជាចុងបញ្ចប់ ហើយនិងយោងទៅសំនួរខាងដើម ថាតើថ្មីៗនេះ ព្យុះដ៏ធំបំផុតនិង ផ្លាស់ប្តូរជាពពកដែលរសាត់តែប៉ុណ្ណោះឬ?

តាមយោបល់មួយចំនួននៃអង្គការអន្តរជាតិដែលអាចដឹងបាននោះហាក់បីដូចជាមានភាពប្រាកដនិយម។ The World Bank ឲ្យលើកឡើងថា "តំលៃដំណាំស្បៀងគឺទំនង ជានៅតែល្អពីឆ្នាំ ២០០៤ ដល់ ២០១៥ បើទោះបីវាមានបរិមាណច្រើនជាងនេះទៀតក៏ដោយ។" The International Food Policy Research Institute មានការកំនត់ចំណាំថា "វិស័យកសិកម្មពិភពលោកបានឈានចូលដំណាក់កាលគ្រោះថ្នាក់ថ្មី, មិនអាចទ្រាំទ្របាន និងដ៏ប៉ិនប្រសព្វ" ចំណែកឯ The Economist Magazine និយាយថា "យុគរបស់តំលៃស្បៀងទាបគឺកន្លងផុតហើយ" ។

# សៀវភៅ គេហទំព័រហើយធនធានមួយចំនួនទៀតរបស់ ECHO




## សំឡេងពីតំបន់ព្រៃឈើ៖ ការបញ្ចូលចំណេះដឹងជនជាតិភាគតិចទៅក្នុងការធ្វើកសិកម្មប្រកបដោយនិរន្តរភាពនៅតំបន់ខ្ពង់រាប

បានកែសំរួលដោយ *Malcolm Cairns. Copyright 2007 by Resources for the future (Washington, DC). 826 pages*
ពិនិត្យឡើងវិញដោយ *Rick Burnette*

ការធ្វើកសិកម្មពនេចរបានក្លាយជាបញ្ហាមួយដ៏ធំ។ ការបណ្តេញចេញ និងសកម្មភាពឧក្រិដ្ឋ ការធ្វើកសិកម្មបង្វិលគឺជាការយល់ច្រឡំមួយដែលគិតថាវាជារឿងតូចតាច។ ក្នុងការឆ្លើយតបលើការប្រឈមមុខផ្លាស់ប្តូរទាំងនេះ ដោយប្រជាជនរាប់លាននាក់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនៅតែពឹងផ្អែកលើការធ្វើកសិកម្មបង្វិល ឬក៏ការធ្វើកសិកម្មផ្សេងទៀត។ ប្រជាជនរស់នៅតំបន់ព្រៃទាំងនោះបានធ្វើការបកស្រាយថា ការអនុវត្តន៍ទាំងនោះគឺពឹងផ្អែកទៅលើការគ្រប់គ្រង ការធ្វើកសិកម្មសំរាប់ជនជាតិភាគតិច។ ការងារទាំងនេះបានផុសចេញនៅឆ្នាំ ១៩៩៧ នៅក្នុងសិក្ខាសាលាថ្នាក់តំបន់ស្តីអំពី (យុទ្ធសាស្ត្ររបស់ជនជាតិភាគតិច សំរាប់ការធ្វើកសិកម្មពនេចរ នៅក្នុងតំបន់អាស៊ីខាងត្បូង) ដែលបានរៀបចំឡើង ដោយមជ្ឈមណ្ឌលកសិ-រុក្ខកម្មពិភពលោក (ICRAF) ដែលមានទីតាំងថ្នាក់តំបន់នៅក្នុងទីក្រុង Bogor ប្រទេស ឥណ្ឌូនេស៊ី។

មានការសិក្សាចំនួន ៦៥ ករណីដែលបានមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលបានបញ្ចូល ការងារទាំងនេះទៅក្នុងការសិក្សា។ មានចំណងជើងសិក្សាឆ្លុះបញ្ចាំងនូវប្រធានបទខុសគ្នា និងទីកន្លែងជាច្រើនខុសៗគ្នាដូចជា (ការគ្រប់គ្រង *Mimosadiplotricha* var. *inermis* ដែលកើតឡើងដំណាលគ្នាប្រទេសថៃភាគខាងត្បូង) និងការគ្រប់គ្រង ដីទំនេររបស់ជនជាតិភាគតិច នៅកោះយ៉ាប)។ តាម

រយៈអត្ថបទស្រាវជ្រាវសរសេរ ដោយអ្នកស្រាវជ្រាវនៅថ្នាក់តំបន់ និងអន្តរជាតិ ដែលអត្ថបទទាំងនេះមិនបានជំរុញឲ្យមានការអានបានទូលំទូលាយ។ ជាមួយនិងមហិច្ឆតាចង់ឲ្យអ្នកស្រាវជ្រាវជាច្រើន ស្តាប់អ្នកអនុវត្តន៍ការអភិវឌ្ឍន៍ និងកសិករជាច្រើនមានគោលបំណងចង់ឲ្យជនជាតភាគតិចអនុវត្តន៍ និងដកបទពិសោធន៍ឲ្យបានកាន់តែច្រើន និងមានភាពកាន់តែប្រសើរដើម្បីឲ្យមានការយល់ដឹងកាន់តែទូលំទូលាយ។

របៀបវារៈដែលចេញពីជនទាំងនោះ គឺដើម្បីឲ្យមានការផ្លាស់ប្តូរគំនិតអវិជ្ជមាន នៃការធ្វើកសិកម្មពនេចរ។ ទោះជាយ៉ាងណាក៏ដោយសៀវភៅនេះបានគ្របដណ្តប់ដល់អ្នកអនុវត្តបច្ចេកទេសកសិកម្ម ដែលមានការយល់ដឹងច្រើន រួមមាន ការដាំដំណាំដោយប្រើដីស្រស់ និងការគ្រប់គ្រង *Imperata* នៅតំបន់វាលស្មៅ។ ដូចដែល Malcolm Cairns បានថ្លែងនៅទំព័រ ខាងមុខដែលនិយាយអំពីការអនុវត្តន៍ដ៏ល្អ ដែលជាគំនិតច្នៃប្រឌិតសាកល្បរបស់កសិករ និងអាចធ្វើឲ្យយើងចង់បាននិងធ្វើការចែករំលែកយ៉ាងទូលំទូលាយ នៅក្នុងសហគមន៍ទៅដល់អ្នក ដែលធ្វើកសិកម្មពនេចរដែលកំពុងស្វែងនូវវិធីសាស្ត្រ ដើម្បីដោះស្រាយការដាំដុះ នៅលើដីដែលមានបញ្ហា និងសេដ្ឋកិច្ចទីផ្សារ។ អ្នកធ្វើកសិកម្មបង្វិល នឹងមិនអាចទទួលផលប្រយោជន៍ តែមួយប៉ុណ្ណោះទេពីការចងក្រង ករណីសិក្សាដ៏ល្អ។ សក្តានុពលមួយទៀតនោះនរណាម្នាក់ ដែលកំពុងធ្វើការជាមួយអ្នកដាំដំណាំ បង្វិលនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ឬក៏ក្រុមផ្សេងៗទៀត នៅជាមួយកសិករជនជាតិភាគតិច នឹងអាចទទួលផលប្រយោជន៍ពីការបោះពុម្ពឯកសារនេះ។

*Voices from the Forest* មានលក់នៅ Amazon.com តាម http://www.amazon.com/Voices-Forest-Integrating-Indigenous-Sustainable/dp/1891853910/ref=pd_bbs_sr_2?ie=UTF8&s=books&qid=1237085932&sr=8-2. តំលៃ US$100.00 (ក្របសៀវភៅរឹង) US$42.00 (ក្របសៀវភៅស្តើង), បូកទាំងថ្លៃដឹកជញ្ជូន